# គំនូរក្នុងព្រះវិហារវត្តព្រះស៊ីសុវត្ថិរតនារាម(ភាគ១)

## ១- ព័ត៌មានទូទៅ

ព្រះវិហារជាកន្លែងចាំបាច់បំផុតផ្នែកជំនឿ សាសនាក្នុងសង្គមខ្មែរ។ ស្ថិតក្នុងបរិបទនេះហើយ បានជាវត្តនីមួយៗត្រូវតែមានព្រះវិហារជាដាច់ខាត ទោះបីជាមានទំហំតូច ឬធំយ៉ាងណានោះ ក៏សំណង់ព្រះវិហារទាំងនោះកសាងឡើងដោយការខិតខំប្រឹងប្រែង និងយកចិត្តទុកដាក់យ៉ាងផ្ចិតផ្ចង់ពីសំណាក់មជ្ឈដ្ឋានបរិស័ទចំណុះជើងវត្ត និងម្ចាស់សទ្ធាដើម្បីឱ្យស័ក្តិសមជាទីកន្លែងគោរពសក្ការៈ។ យ៉ាងណាមិញចំពោះសំណង់ព្រះវិហារវត្តព្រះស៊ីសុវត្ថិរតនារាមហៅវត្តជ្រោយតាកែវ[១] ស្ថិតនៅភូមិ ជ្រោយតាកែវ ឃុំ ជ្រោយតាកែវ ស្រុកកោះធំ ខេត្តកណ្តាល ជាសំណង់វិហារបុរាណមួយនៅប្រប់មាត់ទន្លេដែលមានអាយុ ១១៨ឆ្នាំជាអារាមដ្ឋានអ្នកភូមិជ្រោយតាកែវតាំងពីដើមស.វ.ទី២០(រូបលេខ១ដល់៥)។



រូបលេខ១ រូបព្រះវិហារជ្រុងនិរតី

[១] ពាក្យ ជ្រោយតាកែវ ហៅទៅលើទីដីដែលលយចូលមាត់ទន្លេដែលអ្នកស្រុកនិទានថាកាលពីដើមឡើយទីតាំងភូមិសាស្ត្រនេះជាដីរបស់តាកែវ។ ក្រោយមក តាកែវ បានក្លាយជាអ្នកតាកែវ។

អត្ថបទដោយៈ រឹម ទិត្យបញ្ញា



រូបលេខ២ រូបព្រះវិហារជ្រុងអាគ្នេយ៍



រូបលេខ៣ រូបព្រះវិហារជ្រុងទក្សិណ

អត្ថបទដោយ៖ រឹម ទិត្យបញ្ញា



រូបលេខ២៨ រូបព្រះវិហារជ្រុងបូព៌ា



រូបលេខ២៩ ដំបូលខាងកើត

ព្រះវិហារនេះកសាងឡើងក្នុង ព.ស.២៤៤៩ គ.ស.១៩០៥ ដោយព្រះរាជូបត្ថម្ភព្រះរាជទ្រព្យផ្ទាល់ព្រះអង្គរបស់សម្តេចព្រះបាទព្រះស៊ីសុវត្ថិ ជាព្រះរាជាធិបតីក្នុងសាងសង់លុះគ្រាតែរួចរាល់ចប់សព្វគ្រប់បរិបូណ៌រហូតបញ្ចុះសីមាធ្ងន់(រូបលេខ២៦)។

អត្ថបទដោយៈ រឹម ទិត្យបញ្ញា




រូបលេខ២៦ ច្រកចូលខាងបច្ចិម

ជាលក្ខណៈសម្គាល់ពិសេសមួយនៅក្នុងក្បាច់គោមប្រជាប់ចំកណ្ដាលជញ្ជាំងខាងកើតមានរូបព្រះរាជសង្ហាហើយក្នុងនោះមានអក្សរ **S** នៅចំពីក្រោមជើងពាន។ លក្ខណៈដូចគ្នានេះផងដែរនៅលើក្បាច់ស៊ុមទ្វារខាងកើត ច្រកចូលខាងស្ដាំ នៅក្នុងក្បាច់ស៊ុមទ្វារភ្ញីទេស នៅចំកណ្ដាលផ្ទៃក្បាច់មានរូបព្រះសង្ហាហើយនៅក្រោមជើងពានមានអក្សរ ស ជាទម្រង់អក្សរកាត់។ អក្សរ **S** ស ជាអក្សរកាត់សម្គាល់ព្រះនាមព្រះមហាក្សត្រ **S** មកពីពាក្យ **Sisowath** និង ស មកពីពាក្យ ស៊ីសុវត្ថិ(រូបលេខ២៧ ដល់១០)។





រូបលេខ២៧ ៨

អត្ថបទដោយៈ រឹម ទិត្យបញ្ញា



រូបលេខ៩

ព្រះវិហារនេះបានឆ្លងកាត់សម័យកាលជាច្រើនដំណាក់កាល។ សម័យកាលដែលធ្វើឱ្យព្រះវិហារនេះទទួលរងការខូចខាតមកដល់បច្ចុប្បន្នគឺសម័យ ប៉ុល ពត។ ចាប់ពីថ្ងៃទី ១៧ ខែមេសា ឆ្នាំ១៩៧៥ ប្រទេសកម្ពុជាបានធ្លាក់ចូលក្នុងកណ្ដាប់ដៃពួកខ្មែរក្រហមគ្រប់វត្តអារាមត្រូវបានបង្ខំឱ្យបិទទ្វារ ព្រះសង្ឃត្រូវបង្ខំឱ្យលាចាកសិក្ខាបទ។ ក្នុងនោះផងដែរ វត្តព្រះស៊ីសុវត្ថិរតនារាមបានក្លាយជាកន្លែងឃុំឃាំង មន្ទីរពេទ្យ រោងកាត់ដេរ រោងផលិតថ្នាំពេទ្យ ឯព្រះវិហារក្លាយជាជង្រុកស្រូវ។ រីឯបេតិកភណ្ឌរបស់វត្តមានព្រះពុទ្ធបរិមាតូច ធំ ចេតិយហ្លួងត្រូវវាយកម្ទេចចោលទាំងអស់គ្មានសេសសល់។[២]

ក្រោយពីសម័យខ្មែរក្រហមដួលរលំគំនូរក្នុងព្រះវិហារ រងការខូចខាតមួយចំនួនធំដោយសារតែកត្តាធម្មជាតិ សត្វ អាយុកាល និងកង្វះការថែទាំ ព្រមទាំងកត្តាមនុស្សផង។ ពុទ្ធបរិស័ទចំណុះជើងវត្តបានចូលរួមយ៉ាងសកម្មដើម្បីរៀបចំវត្តឡើងវិញដោយ ប្រធាន

[២] សូមអានៈ ឡាញ់ សារឿន,ប្រវត្តិវត្តព្រះស៊ីសុវត្ថិរតនារាម, ២០១២

អត្ថបទដោយៈ រឹម ទិត្យបញ្ញា

គណៈកម្មាធិការប្រជាជនបដិវត្តន៍ឃុំជ្រោយតាកែវបានជ្រើសតាំងឧបាសក៣រូប ឱ្យឡើងជាគណៈកម្មការចាត់ចែងកិច្ចការក្នុងវត្តមានចំនួន៣រូប ក្រោយមកបានជ្រើសតាំងបន្ថែមទៀតជាបន្តបន្ទាប់។ ផ្នែកអាចារ្យវត្តដំបូងមានតែ១រូប ក្រោយមកទើបជ្រើសតាំងបន្ថែមទៀត។ អាចារ្យគណៈកម្មការទាំងនោះបានខិតខំខ្នះខ្នែងជួសជុលឡើងវិញនូវសមិទ្ធផលខូចខាត ស្វែងរកព្រះពុទ្ធរូបមកតម្កល់នៅលើសាលាបុណ្យ កសាងព្រះអង្គជីវ័ថ្មី។[៣]

គំនូរនៅក្នុងព្រះវិហារ ជាប្រភេទគំនូរបុរាណគូរនៅក្នុងឆ្នាំ១៩០៥ ដោយឧកញ៉ាទេពនិម្មិតម៉ក់។ គំនូរនេះចែកជា៥ផ្នែកគឺ ផ្នែកទី១លើជើងជញ្ជាំងគូររូបទេព ផ្នែកទី២ចន្លោះទ្វារ បង្អួច គូររឿងទសជាតក៍ ផ្នែកទី៣លើមាត់ទ្វារ បង្អួច គូររឿងបឋមសម្ពោធិ ផ្នែកទី៤លើក្បាលជញ្ជាំងគូររូបទេព និងផ្នែកទី៥ គូរលើសន្ទឹកទ្វារ សន្ទឹកបង្អួចរូបទេព។ លុះដល់សម័យខ្មែរក្រហមគំនូរត្រូវរងការខូចខាតយ៉ាងធ្ងន់ធ្ងរ ហេតុនេះទើបធ្វើឱ្យគំនូរមួយចំនួនធំត្រូវជួសជុលក្នុងចន្លោះឆ្នាំ១៩៨០-១៩៩០ដោយលោក ប៊ូ ម៉េង(រូបលេខ១០)។




រូបលេខ១០

[៣] តាមព្រះថេរដីកាភិក្ខុព្រះនាម ហ៊ូ ហ៊ន ព្រះអនុគណស្រុកកោះធំ

អត្ថបទដោយៈ រឹម ទិត្យបញ្ញា

## ឯកសារពិគ្រោះ

ឡាញ់ សារឿន

២០១២ ប្រវត្តិវត្តព្រះស៊ីសុវត្ថិរតនារាម

ពុទ្ធសាសនបណ្ឌិត្យ

១៩៥១ វចនានុក្រមខ្មែរភាគ១ បោះពុម្ពលើកទី១ ភ្នំពេញ

ព្រាប ចាន់ម៉ារ៉ា

២០១៧ ទម្រង់សំណង់ប្រពៃណីខ្មែរភាគ១ ភ្នំពេញ

AMS
អរិយធម៌ខ្មែរ
KHMER CIVILIZATION